សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០)

ឯកសារលេខ D308/3/1/8

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**D308/3/1/8**

**អង្គបុរេជំនុំជម្រះ**

Pre-Trial Chamber
Chambre Preliminaire

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥០)

| | | |
|---|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន | ជាប្រធាន |
| | ចៅក្រម Olivier BEAUVALLET | |
| | ចៅក្រម និយ ថុល | |
| | ចៅក្រម Kang Jin BAIK | |
| | ចៅក្រម ហួត វុទ្ធី | |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 08 / 2017
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សម្ងាត់**

**សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅ នឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឲ្យដាក់សារណា**

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តី អ៊ឹម ចែម:</u>**

ប៊ិត ស៊ាងលីម
Wayne JORDASH

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C. * C.E.T.C.

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ" ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ("សំណើ")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីសម្រេចនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ដោយបានលើកលែងបទចោទទាំងអស់នៅក្នុងសំណុំរឿង ០០៤/១[2] ហើយនៅថ្ងៃដដែលនោះ បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ("ដីកាសម្រេចបដិសេធ")[3]។

2. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) ("ដីកាដំណោះស្រាយ")[4] ដែលសហព្រះរាជអាជ្ញាបានដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ ("បណ្ដឹងឧទ្ធរណ៍")[5]។

3. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិបានដាក់សំណើ។ នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីការពារក្ដី អ៊ុម ថែម បានដាក់

---

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/១") សំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/4 ("សំណើ")។

[2] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្ដី) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D308។

[3] សំណុំរឿង ០០៤/១ ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D307។

[4] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3។

[5] សំណុំរឿង ០០៤/១ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1 ត្រូវបានជូនដំណឹងនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ចម្លើយតប[6] ហើយនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ[7] និងសហព្រះរាជអាជ្ញាអន្តរជាតិ[8] បានដាក់ការឆ្លើយតប។

## II. សារណា

4. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិស្នើសុំពន្យារពេលរហូតដល់ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧ ក្នុងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង និងសុំការអនុញ្ញាតដាក់ចម្លើយតបរបស់របស់ខ្លួនជាភាសាអង់គ្លេសសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក[9]។ គាត់លើកឡើងថា សំណើសុំពន្យារពេលមានយុត្តិកម្មសំអាងហេតុជាចាំបាច់ ដោយពិចារណាដល់ភាពស្មុគ្រស្មាញនៃបញ្ហានានាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ និងនៅក្នុងបណ្តឹងឧទ្ធរណ៍ ព្រមទាំងការថយចុះនូវធនធានដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលបាននាពេលបច្ចុប្បន្ន[10]។ គាត់អះអាងបន្ថែមថា សំណើសុំ

---

[6] សំណុំរឿង ០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ (D308/3/1/4) ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/5 ("ចម្លើយតប")។

[7] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម (D308/3/1/5) ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/6 ("ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

[8] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/7 ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")។

[9] សំណើ កថាខណ្ឌ ១។

[10] សំណើ កថាខណ្ឌ ២។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដាក់ចម្លើយតបរបស់គាត់ជាភាសាអង់គ្លេសសិន មានយុត្តិកម្ម ដោយសារអង្គភាពបកប្រែភាសាពុំអាចបកប្រែឯកសារនេះចប់សព្វគ្រប់មុនខែ វិច្ឆិកា ឆ្នាំ ២០១៧ បានទេ[11]។

5. សហមេធាវីការពារក្តី អ៊ឹម ចែម ឆ្លើយតបថា ទាំងសំណើ និងចម្លើយតបនាពេលខាងមុខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិទៅនឹងបណ្តឹងឧទ្ធរណ៍គួរតែត្រូវបានច្រានចោល ដោយសារកង្វះ*ការជាប់ពាក់ព័ន្ធទៅនឹងព្យសនកម្ម* (locus standi)[12]។ ពួកគេលើកឡើងថា ដោយសារអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិមិនបានជំទាស់តវ៉ាទៅនឹងដីកាសម្រេចបដិសេធ ពួកគេលែងត្រូវបានចាត់ទុកជាភាគីនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/១ ទៀតហើយ ហេតុនេះពួកគេពុំមានសិទ្ធិក្នុងការបញ្ចេញយោបល់ឡើយ[13]។ សហមេធាវីអះអាងបន្ថែមថា ទោះបីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានឋានៈក្តី តែព្យសនកម្មដែលពួកគេបានលើកឡើងថាបានទទួលរង ក៏មិនជាប់ទាក់ទងទៅនឹងបទចោទប្រកាន់ អ៊ឹម ចែម ដែរ[14]។ ពួកគេយល់ឃើញថា សំណើគឺជាការស្នះស្នែង*ដាក់ស្តែង*ដែលមិនអាចទទួលការអនុញ្ញាត ក្នុងការដាក់សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលមិនទាន់ពេលវេលា ដែលជាការល្មើសទៅនឹងវិធានផ្ទៃក្នុង[15]។

6. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិមិនយល់ស្របថា ការមិនបានជំទាស់តវ៉ាទៅនឹងដីកាសម្រេចបដិសេធ ធ្វើឱ្យបាត់បង់សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ពីសំណុំរឿង ០០៤/១ ទេ ដោយសារថា វាជាបញ្ហាកង្វះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទៅលើ អ៊ឹម ចែម ទាំងស្រុង មិនមែនជាកំហុសផ្នែកនីតិវិធីនៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ[16]។ គាត់ឆ្លើយតបថា គេពុំអាចជំទាស់តវ៉ាទៅនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួន

---

[11] សំណើ កថាខណ្ឌ ៣។

[12] ចម្លើយតប កថាខណ្ឌ ២, ១៣។

[13] ចម្លើយតប កថាខណ្ឌ ២, ១៣-១៥។

[14] ចម្លើយតប កថាខណ្ឌ ១៦។

[15] ចម្លើយតប កថាខណ្ឌ ១៣, ១៧-១៩។

[16] ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥។



អង្គជំនុំជម្រះសាលាដំបូង PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ជាដើមបណ្តឹងរដ្ឋប្បវេណីបានទេ ដោយសារមូលដ្ឋានគតិយុត្តិរបស់ដីកាសម្រេចបដិសេធ និង អង្គហេតុដែលថា យុត្តិកម្មគតិយុត្តិដែលជាមូលដ្ឋានរបស់ដីកានេះមិនត្រូវបានចេញនៅឡើយទេ រហូតដល់ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧[17]។ គាត់គូសបញ្ជាក់អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់[18] និងសារៈសំខាន់នៃការអនុវត្តឱ្យពួកគេអាចបញ្ចេញមតិយោបល់ទៅលើបញ្ហានានាដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ ដើម្បីជាប្រយោជន៍យុត្តិធម៌[19]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិលើកឡើងបន្ថែមថា សារណារបស់គាត់នឹងមិនលើកឡើងនូវមូលដ្ឋានថ្មីៗនៃបណ្តឹងឧទ្ធរណ៍ទេ តែលើកឡើងនូវ "យុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក នៅក្នុងផ្នែកនៃ [ដីកាដំណោះស្រាយ] ពោលគឺ ផ្នែក ២.១.១ ដែលផ្តោតទៅលើជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា"[20]។ តាមយោបល់របស់គាត់គឺថា ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទទួលរងឥទ្ធិពលយ៉ាងធំធេងដោយការសន្និដ្ឋានថា ការបង្កើត អ.វ.ត.ក មានគោលបំណងដកហូតយុត្តាធិការទៅលើឧក្រិដ្ឋកម្មទាំងអស់ផ្សេងទៀតដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពីតុលាការជាតិនៅកម្ពុជា[21]។ ជាជម្រើសម្យ៉ាងទៀត គាត់ស្នើសុំឱ្យអង្គបុរេជំនុំជម្រះអនុញ្ញាតឱ្យដាក់សេចក្តីកត់សម្គាល់មួយចំពោះសំណុំរឿង ០០៤/១ ឬអនុញ្ញាតឱ្យដាក់សារណា*របស់អ្នកដែលមិនមែនភាគីក្នុងរឿងក្តី*[22]។

7. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា សហមេធាវីការពារក្តី អ៊ឹម ចែម ដាក់បញ្ចូលគ្នាជារឿងតែមួយនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងការបដិសេធចំពោះពាក្យសុំរបស់ពួកគេ អនុលោមតាមវិធាន ២៣*ស្ទួន*(៣) ៧៧*ស្ទួន* និង ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង និងសិទ្ធិរបស់ពួកគេក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អនុលោមតាមវិធាន

---

[17] *ដូចយោងខាងលើ*។

[18] ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣-៥។

[19] ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤។

[20] ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧។

[21] ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦, ៨។

[22] ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៩-១០។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

៧៤(៤)(ខ)[23]។ នៅក្នុងរឿងក្តីនេះ ដោយសារមូលហេតុតែមួយគត់សម្រាប់ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺជាសេចក្តីសន្និដ្ឋានទៅលើយុត្តាធិការបុគ្គល នៅក្នុងបរិបទនៃការលើកលែងការចោទប្រកាន់នោះ ការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធជារឿងឥតប្រយោជន៍[24] ហើយការសន្និដ្ឋានថាពុំមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នឹងបដិសេធមិនឱ្យមានដំណោះស្រាយតែមួយគត់ដែលបើកចំហសម្រាប់ពួកគេ[25]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងបន្ថែមថា ពុំមានការសម្រេចលើអង្គហេតុចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយថា សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងព្យសនកម្មដែលបានលើកឡើងថាបានទទួលរងនោះនឹងក្លាយជាបុរេវិនិច្ឆ័យទៅលើបញ្ហាស្នូលនានានៃបណ្តឹងឧទ្ធរណ៍មិនខាន[26]។ ចុងក្រោយ គាត់អះអាងថា វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុង គួរត្រូវបានបកស្រាយដើម្បីឱ្យស្របជាមួយនឹងគម្រោងចូលរួមយ៉ាងពេញលេញរបស់ អ.វ.ត.ក ជាពិសេសទៅលើអ្វីដែលសំខាន់ និងជាស្ថាពរ ដូចការលើកលែងការចោទប្រកាន់[27]។

## III. ពិភាក្សា

8. អង្គបុរេជំនុំជម្រះសូមរម្លឹកថា វិធាន ២៣ស្ទួន(២) និង ២៣ស្ទួន(៣) នៃវិធានផ្ទៃក្នុងចែងថា៖

> ២. ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ [...]។ សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ។ ដីកានេះត្រូវបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍សង្ខេប ទៅអង្គបុរេជំនុំជម្រះ ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងសេចក្តីណែនាំអនុវត្ត។ បណ្តឹងឧទ្ធរណ៍សង្ខេបនេះ មិនផ្អាកដំណើរការនីតិវិធីទេ។ *លើកលែង និងលុះត្រាតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបដិសេធចោល*

[23] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ២។

[24] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣។

[25] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៥។

[26] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៦។

[27] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧-៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C E.C.T.C

*អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចអនុវត្តសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីបាន* [សេចក្តីបញ្ជាក់បន្ថែម]។

៣. នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍សង្ខេប ដោយភាគី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមានចែងក្នុងវិធាន ៧៧ស្ទួន។ បណ្តឹងឧទ្ធរណ៍សង្ខេបនេះមិនផ្អាកដំណើរការនីតិវិធីទេ។ [...]"

9. វិធាន ៧៤(៤)(ខ) និង (ច) ចែងបន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត "ដែលមិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" និង ប្រឆាំងនឹង "ដីកាលើកលែងការចោទប្រកាន់ ក្នុងករណីដែលសហព្រះរាជអាជ្ញា ធ្វើបណ្តឹងឧទ្ធរណ៍ដែរ"។

10. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពុំបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធ អនុលោមតាមវិធាន ៧៤(៤)(ខ) និង ៧៧ស្ទួន នៃវិធានផ្ទៃក្នុងឡើយ ហើយក៏មិនបានព្យាយាមដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អនុលោមតាមវិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុងនោះដែរ។ ប៉ុន្តែ ពួកគាត់ស្នើសុំពន្យារពេលដើម្បីអនុវត្តសិទ្ធិចូលរួមរបស់ខ្លួនតាមរយៈការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ។

11. ទោះបីជាអង្គបុរេជំនុំជម្រះទទួលស្គាល់សិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រួមមាន សិទ្ធិដាក់ចម្លើយតប និងការឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ភាគីដទៃទៀត និងជាទូទៅក្នុងគោលបំណងដើម្បី "គាំទ្រដល់ការចោទប្រកាន់" ក៏ដោយ ក៏អង្គបុរេជំនុំជម្រះកត់សម្គាល់បុព្វសិទ្ធិនីតិវិធីបែបនេះផ្តល់ឲ្យសម្រាប់តែដើមបណ្តឹងរដ្ឋប្បវេណីដែលជាក់ស្តែងចូលរួមក្នុងកិច្ចដំ

ណើរការនីតិវិធីប៉ុណ្ណោះ[28]។ ជាពិសេស នៅដំណាក់កាលស៊ើបសួរ ទោះបីជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្លាយជាភាគី និងមានសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ២៣ស្ទួន(២) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ពួកគាត់អាចអនុវត្តសិទ្ធិចូលរួមបាន "*លុះត្រាតែត្រូវបានបដិសេធ*" ប៉ុណ្ណោះ។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ដោយមានការបដិសេធ និងដោយខកខានមិនបានប្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេចបដិសេធនោះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ មិនអាចចាត់ទុកតាមផ្លូវច្បាប់ថាជាភាគីនៃកិច្ចដំណើរការនីតិវិធីតទៅទៀតបានទេ ដូច្នេះហើយពួកគាត់មិនអាចអនុវត្តបុព្វសិទ្ធិនីតិវិធីក្នុងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍បានទេ។

12. ទោះបីយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះទទួលស្គាល់លក្ខណៈពិសេសនៃរឿងក្តី និងអង្គហេតុដែលថា ដីកាសម្រេចបដិសេធជាប់ទាក់ទងដោយស្វ័យប្រវត្តិទៅនឹងដីកាដំណោះស្រាយដែលលើកលែងការចោទប្រកាន់ទាំងមូល។ អង្គបុរេជំនុំជម្រះក៏យល់ឃើញផងដែរថា ដោយពិចារណាទៅលើសារៈសំខាន់នៃបញ្ហានានាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ និងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ វាជាផលប្រយោជន៍នៃយុត្តិធម៌ក្នុងការផ្តល់ឱកាសឱ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិបញ្ចេញនូវទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់តំណាងឱ្យ ជាពិសេសប្រសិនបើសេចក្តីសន្និដ្ឋានរបស់គាត់កំណត់ត្រឹមបញ្ហាជាក់លាក់អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (ផ្នែក ២.១.១ នៃដីកាដំណោះស្រាយ)[29]។ អង្គបុរេជំនុំជម្រះយល់ស្របទៀតថាការធ្វើសេចក្តីសន្និដ្ឋានណាមួយអំពីទំនាក់ទំនងរវាងព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង និងការចោទប្រកាន់នានានោះ គឺជាការមិនពាក់ព័ន្ធឡើយនៅក្នុងដំណាក់កាលនេះ។

13. ដោយពិចារណាទៅលើហេតុផលខាងលើ ផ្អែកលើយុត្តាធិការឥស្សរចិត្តរបស់ខ្លួន និងទៅលើវិធាន ៣៣ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះស្នើឱ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ដាក់

[28] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ F10/2 កថាខណ្ឌ ១១-១៥។

[29] សូមមើល ការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦-៧។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. CHAMBRE PRÉ

សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០)

ឯកសារលេខ D308/3/1/8

សារណាមិនឱ្យលើសពីចំនួន ១៥ ទំព័រ ដែលកម្រិតត្រឹមបញ្ហាជាក់លាក់អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (ផ្នែក ២.១.១ នៃដីកាដំណោះស្រាយ) នៅត្រឹមថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧ ជាភាសាអង់គ្លេសជាមុនសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។ អង្គបុរេជំនុំជម្រះអនុញ្ញាតបន្ថែមទៀតឱ្យភាគីនានាឆ្លើយតបទៅនឹងសារណារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ នៅក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណានេះជាភាសាអង់គ្លេស និងភាសាខ្មែរ។

**យោងតាមហេតុផលខាងលើនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **បដិសេធ** សំណើនេះ។

- **ស្នើ** ឱ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ដាក់សារណាមិនឱ្យលើសពីចំនួន ១៥ ទំព័រ ដែលកម្រិតត្រឹមបញ្ហាជាក់លាក់អំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (ផ្នែក ២.១.១ នៃដីកាដំណោះស្រាយ) នៅត្រឹមថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៧ ជាភាសាអង់គ្លេសជាមុនសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

- **អនុញ្ញាត** ឱ្យភាគីនានាដាក់ចម្លើយតបដែលមានចំនួន ១៥ ទំព័រ ទៅនឹងសារណារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ នៅក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណានេះជាភាសាអង់គ្លេស និងភាសាខ្មែរ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** Olivier BEAUVALLET **ន័យ ធុល** Kang Jin BAIK **ហួត វុទ្ធី**